00345995

ឯកសារដើម: D97/9

នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 29 / 06 / 2009
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A.Fuy

| | |
|---|---|
| **សំណុំរឿងលេខ:** | ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស |
| **ដាក់ទៅ:** | សហចៅក្រមស៊ើបអង្កេត |
| **ថ្ងៃដាក់:** | ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៩ |
| **ភាគីអ្នកដាក់:** | សហមេធាវីរបស់លោក អៀង សារី |
| **ភាសាដើម:** | អង់គ្លេស |
| **ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** | សាធារណៈ |

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 02 / JUL / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A.Fuy

---

**សំណើរបស់លោក អៀង សារី សុំអោយដាក់ទណ្ឌកម្មតាមវិធានផ្ទៃក្នុង ៣៥ ដោយសារសហព្រះរាជអាជ្ញា បានបំភ័ន្តតុលាការនៅក្នុងការដាក់សេចក្តីសង្ខេបបន្ថែមស្តីពីសហកម្មឧក្រិដ្ឋកម្មរួម ដែលបានដាក់ធ្វើនៅថ្ងៃទី ៣១ ធ្នូ ២០០៨**

---

| **អ្នកដាក់ឯកសារ៖** | **អ្នកទទួលឯកសារ៖** |
|---|---|
| **សហមេធាវីរបស់លោក អៀង សារី** | **សហចៅក្រមស៊ើបអង្កេត** |
| លោក អាង ឧត្តម | ចៅក្រម យូ ប៊ុនឡេង |
| លោក Michael G. KARNAVAS | ចៅក្រម Marcel LEMONDE |

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") អនុលោមទៅតាមវិធាន ៣៥(១) នៃវិធានផ្ទៃក្នុង តទៅនេះ សូមស្នើដល់ការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") សុំអោយស្វែងរកអោយឃើញថា សមាជិកនានានៃការិយាល័យសហព្រះរាជអាជ្ញា ("ក.ស.ព") មានការទទួលខុសត្រូវក្នុងការរំខានកិច្ចដំណើរការនីតិវិធីតុលាការដោយដឹងជាមុននិងដោយមានចេតនា តាមរយៈការបំភ័ន្ត ក.ស.ច.ស ទាក់ទងនឹងការអះអាងដែលមានភ័យរ៉ាប់នៅក្នុង សេចក្តីសង្កេតបន្ថែមស្តីពី សហកម្មឧក្រិដ្ឋកម្មរួម[1] ។ ក្នុងអំឡុងពេលធ្វើបាឋកថាមួយ ដែលធ្វើឡើងដោយសាស្ត្រាចារ្យ Michael Scharf កាលពីថ្ងៃទី ២៤ មិថុនា ២០០៩ ក្រោមចំណងជើងថា "ជា សហកម្មឧក្រិដ្ឋកម្មរួម ឬក៏អត់? ការយល់ដឹងពីតុលាការកម្ពុជា (To JCE or not JCE? Insights from the Cambodia Tribunal)[2]" សាស្ត្រាចារ្យ Michael Scharf បានសារភាពថា ក.ស.ព មានចេតនាលាក់ទុកនូវព័ត៌មានទាក់ទងនឹងការទទួលយក និងវិសាលភាពនៃគោលការណ៍នានាមកពីធម្មនុញ្ញ និងសាលក្រមនានារបស់តុលាការ Nuremberg ("គោលការណ៍ Nuremberg") ដែលអាចនឹងបានធ្វើអោយខូចខាតដល់ឋានៈនៃ JCE នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ[3]។

## I. សេចក្តីផ្តើម

១. មេធាវីការពារក្តី បានដាក់នូវពាក្យសុំជំទាស់របស់ខ្លួនទៅនឹងការអនុវត្តនូវការទទួលខុសត្រូវព្រហ្មទណ្ឌបែប សហកម្មឧក្រិដ្ឋកម្មរួម (ហៅកាត់ថា "JCE") កាលពីថ្ងៃទី ២៨ កក្កដា ២០០៨[4]។

---

[1] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស សេចក្តីសង្កេតបន្ថែមរបស់សហព្រះរាជអាជ្ញាស្តីពីសហកម្មឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ៣១ ធ្នូ ២០០៨ ("សេចក្តីសង្កេតបន្ថែមរបស់ ក.ស.ព")។

[2] Michael Scharf សាស្ត្រាចារ្យច្បាប់នៃមជ្ឈមណ្ឌលច្បាប់អន្តរជាតិ Frederick K. Cox នៃសាកលវិទ្យាល័យច្បាប់ Case Western Reserve បាឋកថាជាស៊េរីនៃច្បាប់ព្រហ្មទណ្ឌSupranational (Supranational Criminal Law Lecture Series) "ជា សហកម្មឧក្រិដ្ឋកម្មរួម ឬក៏អត់? ការយល់ដឹងពីតុលាការកម្ពុជា (To JCE or not JCE? Insights from the Cambodia Tribunal)" ថ្ងៃទី ២៣ មិថុនា ២០០៩ ("បាឋកថារបស់ Scharf")។

[3] Geoff Roberts ជាទីប្រឹក្សាច្បាប់របស់ក្រុមមេធាវីការពារក្តីលោក អៀង សារី ជាមួយនឹង Shona Grundy ជាកម្មសិក្សាការីធ្វើការអោយក្រុមមេធាវីការពារក្តី Jadranko Prlić នៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ទាំងពីរបានចូលរួមមានវត្តមាននៅពេលធ្វើបាឋកថានេះ ។ ការសង្កេតនានាធ្វើឡើងដោយសាស្ត្រាចារ្យ Michael Scharf ដែលបានលើកឡើងជាញឹកញាប់នៅក្នុងសំណើសុំនេះគឺសំអាងទៅលើការប្រមូលចងក្រងឡើងវិញដែលមានចំណែករបស់អ្នកទាំងពីរនេះ។

[4] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស ពាក្យសុំរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌដែលស្គាល់ថាជា សហកម្មឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ២៨ កក្កដា ២០០៨ ("ពាក្យសុំទាក់ទងនឹង JCE")។

ក.ស.ព បានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងពាក្យសុំជំទាស់នេះ កាលពីថ្ងៃទី ១១ សីហា ២០០៨[5]។ ដោយទទួលស្គាល់ពីសារៈសំខាន់នៃបញ្ហានេះ និងដោយសារផលប៉ះពាល់របស់វាមកលើជនត្រូវចោទទាំងអស់ ក.ស.ច.ស បានស្នើអោយភាគីទាំងអស់នៃសំណុំរឿង ០០២ ដាក់សេចក្តីសន្និដ្ឋានបន្ថែមទៅលើបញ្ហានេះ នៅត្រឹមថ្ងៃទី ៣១ ធ្នូ ២០០៨[6]។ មេធាវីការពារក្តី បានដាក់សេចក្តីសង្កេតបន្ថែមរបស់ខ្លួននៅថ្ងៃទី ២៤ វិច្ឆិកា ២០០៨[7] ខណៈពេលដែល ក.ស.ព បានដាក់សេចក្តីសង្កេតបន្ថែមរបស់ខ្លួននៅថ្ងៃទី ៣១ ធ្នូ ២០០៨។

២. បញ្ហាជាសារវ័ន្តនៅក្នុងវិវាទនេះគឺថា តើ JCE ជាផ្នែកនៃ ច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងរវាងឆ្នាំ ១៩៧៥-១៩៧៩ ដែរឬទេ។ បញ្ហានេះត្រូវបានលើកឡើងដោយមេធាវីការពារក្តី នៅក្នុងពាក្យសុំស្តីពី JCE[8] និង សេចក្តីសង្កេតបន្ថែមរបស់មេធាវីការពារក្តី[9] ហើយដែលវាត្រូវបាន ក.ស.ព ឆ្លើយតបយ៉ាងវែងអន្លាយនៅក្នុង ចម្លើយតបរបស់ ក.ស.ព[10] និង សេចក្តីសង្កេតបន្ថែមរបស់ ក.ស.ព[11]។ លើកលែងតែចំណោទនេះត្រូវបានគេបកស្រាយនៅក្នុងន័យវិជ្ជមាន បើមិនអញ្ចឹងទេ ទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌនេះ ពិតជាមិនអាចត្រូវបានគេប្រើប្រាស់ប្រឆាំងនឹងបុគ្គលទាំងឡាយនោះ ដែលត្រូវបានគេចោទប្រកាន់នៅចំពោះមុខ អ.វ.ត.ក ឡើយ។

## II. អង្គច្បាប់

ក. តាម*ក្រមសីលធម៌ចៅក្រម*របស់កម្ពុជាឆ្នាំ ២០០៧[12]

---

[5] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងពាក្យសុំរបស់អៀង សារី ស្តីពីសហកម្មឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ១១ សីហា ២០០៨ (“ការឆ្លើយតបរបស់ ក.ស.ព”)។

[6] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស សេចក្តីបង្គាប់ស្តីពីការអនុវត្តនៅ អ.វ.ត.ក នូទម្រង់នៃការទទួលខុសត្រូវដែលស្គាល់ថាជា សហកម្មឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ១៦ កញ្ញា ២០០៨ (“ដីកាបង្គាប់”)។

[7] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស សេចក្តីសង្កេតបន្ថែមរបស់លោកអៀង សារី ស្តីពីការអនុវត្តនូវទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួមនៅ អ.វ.ត.ក ចុះថ្ងៃទី ២៤ វិច្ឆិកា ២០០៨ (“សេចក្តីសង្កេតបន្ថែមរបស់មេធាវីការពារ”)។

[8] ពាក្យសុំទាក់ទងនឹង JCE កថាខណ្ឌ ១៨ ដល់ ២៤ ។

[9] សេចក្តីសង្កេតបន្ថែមរបស់មេធាវីការពារ កថាខណ្ឌ ៣០ ដល់ ៥៤។

[10] ការឆ្លើយតបរបស់ ក.ស.ព កថាខណ្ឌ ១៨ ដល់ ៣០ ។

[11] សេចក្តីសង្កេតបន្ថែមរបស់ ក.ស.ព កថាខណ្ឌ ៩ ដល់ ២៥ ។

[12] ក្រមសីលធម៌ចៅក្រម ដែលអនុម័តដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម កាលពីថ្ងៃទី ៥ កុម្ភៈ ២០០៧ ។

មាត្រា ១ ចែងថា "នៅក្នុងក្រមសីលធម៌នេះ "ចៅក្រម" មានន័យថា ចៅក្រមអាសនៈ និង ចៅក្រមអយ្យការ" ។

មាត្រា ១៨ ចែងថា "ចៅក្រមត្រូវតែជាបុគ្គលសុច្ចរិត"។

ខ. *វិធាននៃក្រមសីលធម៌វិជ្ជាជីវៈរបស់គណៈមេធាវី*នៃតំបន់ District of Columbia

វិធាន ៣.៣ នៃ បានចែងថា៖

"(ក) មេធាវី ដោយដឹងជាមុន មិនត្រូវ

(១) ធ្វើសេចក្ដីថ្លែងការណ៍អង្គហេតុ ឬអង្គច្បាប់ដែលមិនត្រឹមត្រូវ ដាក់ជូនតុលាការ ឬខកខានមិនបានធ្វើការកែតម្រូវនូវសេចក្ដីថ្លែង ដែលខុសឆ្គងទៅលើភស្តុតាងអង្គហេតុ ឬអង្គច្បាប់ ដែលបានធ្វើឡើងពីមុនជូនតុលាការដោយមេធាវី លើកលែងតែការកែតម្រូវនោះនឹង នឹងតម្រូវអោយលាតត្រដាងនូវព័ត៌មាន ដែលត្រូវបានហាមឃាត់តាមវិធាន ១.៦

[...]

(3) ការខកខានមិនលាតត្រដាងជូនតុលាការនូវមូលដ្ឋានសំអាងផ្លូវច្បាប់ប្រើប្រាស់ជាឯកសារយោង នៅក្នុងការគ្រប់គ្រងយុត្តាធិការ (controlling jurisdiction) ដែលមិនបានលាតត្រដាងដោយមេធាវីបដិបក្ខ ហើយមេធាវីនោះបានដឹងថាជាការសម្រេចឈ្នះចាញ់ទៅលើចំណោទដែលកំពុងចោទឡើង (dispositive of a question at issue) និងជះឥទ្ធិពលដោយផ្ទាល់ទៅលើជំហ(position) របស់កូនក្ដី[13] "

គ. *ក្រមសីលធម៌វិជ្ជាជីវៈមេធាវី*គណៈមេធាវី Quebec[14]

មាត្រា ២.0១.0១ ចែងថា មេធាវីដែលប្រកបវិជ្ជាជីវៈនៅ Quebec "ត្រូវគាំពារអំណាចរបស់តុលាការ" និង "មិនអាចធ្វើសកម្មភាពនៅក្នុងរូបភាពណាមួយដែលធ្វើអោយខូចដល់ដល់កិច្ចដំណើរការនីតិវិធីតុលាការឡើយ"។

ឃ. *វិធានគំរូនៃក្រមសីលធម៌វិជ្ជាជីវៈនៅអូស្ត្រាលី* របស់ប្រទេសអូស្ត្រាលី៖

---

[13] វិធាននេះបានធ្វើវិសោធនកម្ម ហើយមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី ១ កុម្ភៈ ២00៧។ (គូសបញ្ជាក់បន្ថែម) *សូមមើលផងដែរ* មាត្រា ៣.៣ វិធានគំរូនៃក្រមសីលធម៌វិជ្ជាជីវៈ ដែលបានដាក់ចេញដោយគណៈមេធាវីអាមេរិក។

[14] ច្បាប់ទាក់ទងនឹងគណៈមេធាវី Quebec (R.S.Q., c. B-1, s. 15) ក្រមសីលធម៌វិជ្ជាជីវៈ (R.S.Q., c. C-26)។

ផ្នែក ១៤.១ ចែងថា "អ្នកប្រកបវិជ្ជាជីវៈដាច់ខាតមិនត្រូវធ្វើសេចក្ដីថ្លែងការណ៍បំភ័ន្ត ដោយដឹងជាមុនដែលនាំអោយតុលាការយល់ច្រលំឡើយ" [15]។

ង. *ក្រមសីលធម៌គណៈមេធាវីអង់គ្លេស និងWales* របស់ចក្រភពអង់គ្លេស

ផ្នែកទី ១៖ ក្រមសីលធម៌ - ជំពូក VII - ការបំពេញការងារដោយមេធាវីប្រកបវិជ្ជាជីវៈការពារក្ដី (Practising Barristers), មាត្រា ៧០៨ ចែងក្នុងផ្នែកពាក់ព័ន្ធថា៖

"មេធាវីការពារក្ដី (barrister) នៅពេលបំពេញការងារក្នុងកិច្ចដំណើរការនីតិវិធីនៅក្នុងតុលាការ៖

[...]

(គ) ដាច់ខាតត្រូវតែធានាថា តុលាការត្រូវបានជូនដំណឹងអំពីរាល់បញ្ញត្តិច្បាប់ និងសេចក្ដីសម្រេចដែលពាក់ព័ន្ធទាំងអស់ ដែលខ្លួនដឹង ទោះជាវាមានឥទ្ធិពលល្អ (favourable) ឬមិនល្អ (unfavourable) មកលើរឿងវិវាទដែលខ្លួនកំពុងធ្វើទឡ្ហីករណ៍ក៏ដោយ[16]។

ច. តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី

១. *បទដ្ឋានក្រមសីលធម៌វិជ្ជាជីវៈមេធាវីខាងអយ្យការ*[17]

បទបញ្ញត្តិសម្រាប់អយ្យការលេខ ២(ឃ) ចែងថា រដ្ឋអាជ្ញា "ត្រូវប្រើប្រាស់នូវបទដ្ឋានសុច្ចរិតភាព និងការយកចិត្តទុកដាក់ដែលខ្ពស់បំផុត រួមមានទាំងកាតព្វកិច្ចដែលតែងតែធ្វើការងារដោយភាពឆាប់រហ័សនៅពេលដែលចាំបាច់ និងក្នុងគោលបំណងល្អ"។

បទបញ្ញត្តិសម្រាប់អយ្យការលេខ ២(ង) ចែងថា រដ្ឋអាជ្ញា "ត្រូវបង្ហាញនូវការគោរព និងមិនលាក់លៀមនៅចំពោះមុខតុលាការ មិនត្រូវធ្វើសេចក្ដីថ្លែងការណ៍ស្ដីពីអង្គហេតុដែល

---

[15] *វិធានគំរូនៃក្រមសីលធម៌វិជ្ជាជីវៈ* Law Council របស់ប្រទេសអូស្ត្រាលី ខែមីនា ២០០២។

[16] *ក្រមសីលធម៌គណៈមេធាវីអង់គ្លេស និងWales* ឆ្នាំ ២០០៤ អាចស្វែងរកបាននៅគេហទំព័រ៖ http://www.barstandardsboard.org.uk/standardsandguidance/codeofconduct/tableofcontents/

[17] បទបញ្ញត្តិសម្រាប់អយ្យការលេខ ២ (១៩៩) បទដ្ឋានក្រមសីលធម៌វិជ្ជាជីវៈមេធាវីខាងអយ្យការ។ *សូមមើលផងដែរ* មាត្រា ២៤(៣) ក្រមសីលធម៌វិជ្ជាជីវៈមេធាវីនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ICC-ASP/4/Res.1 ដែលចែងថា "មេធាវីមិនត្រូវបញ្ឆោត ឬដោយដឹងជាមុនបំភ័ន្តតុលាការអោយយល់ច្រលំឡើយ ។ មេធាវីត្រូវតែចាត់វាល់វិធានការណ៍ទាំងអស់ជាបន្ទបន្ទាប់ដើម្បីកែតម្រូវ នូវសេចក្ដីថ្លែងការណ៍ខុសឆ្គងណាមួយដែលខ្លួនបានធ្វើ ឬដែលអ្នកជំនួយការ ឬបុគ្គលិករបស់ខ្លួនធ្វើកាន់តែឆាប់តាមដែលអាចធ្វើទៅបាន បន្ទាប់ពីបានដឹងថាសេចក្ដីថ្លែងការណ៍នោះមានកំហុសឆ្គង" ។

មិនត្រឹមត្រូវដោយខ្លួនដឹងជាមុនដាក់ជូនតុលាការ ឬផ្តល់នូវភស្តុតាងដែលមេធាវីខាងអយ្យការដឹងថាវាមិនត្រឹមត្រូវនោះឡើយ" ។

២. *ក្រមសីលធម៌វិជ្ជាជីវៈមេធាវី*[18]

មាត្រា ២៣(ខ) ចែងថា "<u>មេធាវីមិនត្រូវធ្វើសេចក្តីថ្លែងអង្គហេតុ ឬ អង្គច្បាប់ដែលមិនត្រឹមត្រូវដោយខ្លួនដឹងជាមុនដាក់ជូនតុលាការឡើយ</u>"។

ឆ. *ក្រមសីលធម៌វិជ្ជាជីវៈមេធាវី*នៃតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាលេអូន[19]

មាត្រា ៨(ខ) ចែងថា មេធាវីខាងអយ្យការ និងមេធាវីខាងការពារក្តី "មិនត្រូវបញ្ឆោត ឬ ដោយដឹងជាមុន ឬ ដោយការធ្វេសប្រហែស ធ្វើអោយតុលាការពិសេសនេះយល់ខុសឡើយ ។ មេធាវី ត្រូវធ្វើរាល់សកម្មភាពជាបន្តបន្ទាប់ចាំបាច់ទាំងអស់ ដើម្បីកែតម្រូវនូវសេចក្តីថ្លែងការណ៍ខុសឆ្គង ដែលធ្វើឡើងដោយមេធាវី ឬសមាជិកនៃក្រុមរបស់ខ្លួន អោយឆាប់តាមដែលអាចធ្វើទៅបាន បន្ទាប់ពីបានដឹងថាសេចក្តីថ្លែងការណ៍នោះ មានកំហុសឆ្គង" ។

## III. ឧត្តរការណ៍

៣. សេចក្តីសង្កេតបន្ថែមរបស់ខ្លួន ក.ស.ព សំអាងយ៉ាងខ្លាំងក្លាទៅលើ សេចក្តីសម្រេចលេខ ៩៥(១) របស់ មហាសន្និបាតអង្គការសហប្រជាជាតិ ("UNGA") ដែលក្នុងនោះ ក.ស.ព បានអះអាងថា "បានបញ្ជាក់ច្បាស់លាស់ជាឯកច្ឆ័នលើគោលការណ៍ធម្មនុញ្ញ Nuremberg និងសេចក្តីសម្រេចរបស់តុលាការ Nuremberg[20]" ដើម្បីពង្រឹងនូវការអះអាងរបស់ខ្លួនថា JCE គឺជាផ្នែកនៃ ច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ សម្រាប់ ក.ស.ព "សកម្មភាពនេះបានបញ្ជាក់ច្បាស់ថា ទាំងច្បាប់សារធាតុ និងទ្រឹស្តីនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបុគ្គល (រួមមាន ការទទួលខុសត្រូវ "ផែនការរួម") ដែលមានចែងនៅក្នុងធម្មនុញ្ញ Nuremberg និងដែលតុលាការ Nuremberg បានយកមកអនុវត្ត" [21] ។ ក្រោយមក ក.ស.ព បានទទួលស្គាល់នូវការផ្តេកផ្តួលរបស់ខ្លួនទៅលើ សេចក្តីសម្រេចលេខ ៩៥(១) របស់ UNGA ដោយថ្លែងថា "សហកម្មឧក្រិដ្ឋកម្មរួមគឺជា<u>បដិលេខ</u>

---

[18] ដែលត្រូវបានធ្វើវិសោធនកម្មកាលពីថ្ងៃទី ១២ កក្កដា ២00២ (IT/125 Rev. 1) (គូសបញ្ជាក់បន្ថែម)។

[19] អនុម័តកាលពីថ្ងៃទី ១៤ ឧសភា ២00៥ ហើយធ្វើវិសោធនកម្មកាលពីថ្ងៃទី១៣ ឧសភា ២00៦ ។

[20] សេចក្តីសង្កេតបន្ថែមរបស់ ក.ស.ព កថាខណ្ឌ ១២។

[21] *ដូចយោងខាងលើ* ។

ជាសាកល និងមិនមានលក្ខខណ្ឌចំពោះគោលការណ៍ Nuremberg តាំងពីដើមឆ្នាំ ១៩៤៦ [...] ដែលបានបង្កើតទ្រឹស្តីនេះ ក្នុងទម្រង់នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គលក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ" [22]។ ជាលើកទីពីរ ក.ស.ព ក៏បានព្យាយាមបង្កើត JCE នៅក្នុងសំណុំរឿងរបស់ ឌុច ដែលសព្វថ្ងៃកំពុងស្ថិតនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[23]។ នៅក្នុងសំណើរបស់ ក.ស.ព ការសំអាងគឺពឹងផ្អែកទៅលើ "អនុស្សារណៈដ៏ទូលំទូលាយ"ដោយសង្ខេប ដែលធ្វើឡើងដោយ ក.ស.ព នៅក្នុងសំណុំរឿង ០០២ ជាកិច្ចឆ្លើយតបនឹងពាក្យសុំទាក់ទងនឹង JCE ដែលរួមមានសេចក្តីសង្កេតបន្ថែមរបស់ ក.ស.ព ផងដែរ[24]។ អនុស្សារណៈទាំងនេះត្រូវដាក់ភ្ជាប់មកជាឧបសម្ព័ន្ធមួយទៅនឹងសំណើសុំរបស់ ក.ស.ព ។ ហេតុដូច្នេះ ក.ស.ព បានព្យាយាមយកជាសំអាងដូចគ្នាទៅលើការបកស្រាយរបស់ខ្លួនអំពី សេចក្តីសម្រេចលេខ ៩៥(១) របស់ UNGA នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ក៏ដូចជាចំពោះមុខ ក.ស.ច.ស ។

៤. នៅក្នុងការបាថកថារបស់គាត់ សាស្ត្រាចារ្យ Scharf បានលាតត្រដាងថា គាត់ត្រូវបាន ក.ស.ព ជួលអោយមកបំពេញការងារ ក្នុងឋានៈជាជំនួយការពិសេសរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ Robert Petit សម្រាប់រយៈពេលប្រហែលពី ៥ ទៅ ៦ សប្តាហ៍ នៅចុងឆ្នាំ ២០០៨ ។ គាត់ត្រូវបានគេដាក់អោយបំពេញការងារ ស្ទើរតែទាំងស្រុងទៅលើសេចក្តីសង្កេតបន្ថែមរបស់ ក.ស.ព ។ សាស្ត្រាចារ្យ Scharf ទំនងជាត្រូវបានគេល្បួងអោយធ្វើការអោយ ក.ស.ព តាមរយៈសេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញា Petit ដែលថា សារណានេះគឺជាសារណាដែលមានសារៈសំខាន់ជាទីបំផុត ដែលនឹងត្រូវដាក់នៅចំពោះមុខ អ.វ.ត.ក ។ ប្រាកដណាស់ថា Scharf ត្រូវបានគេល្បួងផងដែរ តាមរយៈការសារភាពរបស់សហព្រះរាជអាជ្ញាដែលថា ក.ស.ព ត្រូវការចាំបាច់អោយ អ.វ.ត.ក ត្រូវប្រើប្រាស់នូវ JCE ដោយហេតុថា វាពិតជាមានកង្វះខាតនូវភស្តុតាងផ្ទាល់ដូចជា ការចេញបញ្ជានានា ឬសាក្សីនានាដែលអាចបង្ហាញភស្តុតាងថា "មេដឹកនាំជាន់ខ្ពស់នានា" នៃកម្ពុជាប្រជាធិបតេយ្យ មានការទទួលខុសត្រូវដោយផ្ទាល់ចំពោះឧក្រិដ្ឋកម្មដែលគេចោទប្រកាន់។ រឿងរ៉ាវទាំងពីរនេះត្រូវបានលាតត្រដាងនៅក្នុងការបាថកថារបស់គាត់។

៥. សាស្ត្រាចារ្យ Scharf បានលាតត្រដាងថា បន្ថែមទៅលើ សេចក្តីសម្រេចលេខ ៩៥(១) របស់

---

[22] សេចក្តីសង្កេតបន្ថែមរបស់ ក.ស.ព កថាខណ្ឌ ១៤ ។ (គូសបញ្ជាក់បន្ថែម)

[23] *ករណី កាំង ហ្កេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អជសដ សំណើរបស់សហព្រះរាជអាជ្ញាសុំអោយអនុវត្តសហកម្មឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ៨ មិថុនា ២០០៩ ("សំណើរបស់ ក.ស.ព")។

[24] សំណើរបស់ ក.ស.ព កថាខណ្ឌ ៤០ ។

UNGA ដែល ក.ស.ព បានសំអាងទៅលើយ៉ាងខ្លាំងក្លានោះ នៅមានសេចក្តីសម្រេចរបស់ UNGA មួយបន្ទាប់ពី ៥ឆ្នាំក្រោយមកទៀត ដែលចោទជាចំណោទទៅលើការទទួលយក និងវិសាលភាពនៃគោលការណ៍ Nuremberg។ យោងទៅតាមសាស្ត្រាចារ្យ Scharf សមាជិករបស់ ក.ស.ព បានធ្វើយុទ្ធសាស្ត្រទៅលើថា តើ ក.ស.ព ត្រូវមានកាតព្វកិច្ចតាមក្រមសីលធម៌ ដើម្បីលាតត្រដាងដល់ ក.ស.ច.ស នូវសេចក្តីសម្រេចរបស់ UNGA ក្រោយមកទៀតដែរឬទេ ដែលសេចក្តីសម្រេចនេះប្រាកដជាមានឥទ្ធិពលមិនល្អមកលើគោលជំហររបស់ខ្លួនទាក់ទងនឹងការអនុវត្ត JCE តាមរយៈការយកជាសំអាងសេចក្តីសម្រេចក្រោយនេះ ទៅក្នុងសេចក្តីសង្កេតបន្ថែមរបស់ខ្លួន។ ក.ស.ព បានសម្រេចថា គ្មានកាតព្វកិច្ចសីលធម៌ដើម្បីលាតត្រដាងនូវភាពមិនស្របគ្នាពីតម្លៃកាលពីដំបូងរបស់សេចក្តីសម្រេចលេខ ៩៥(១) របស់ UNGA ឡើយ ថ្វីបើខ្លួនបានសំអាងតែទៅលើសេចក្តីសម្រេចលេខ ៩៥(១) របស់ UNGA តែមួយគត់ សម្រាប់ការអះអាងដាច់ណាត់របស់ខ្លួនថា ការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះផែនការរួម គឺជាផ្នែកនៃគោលការណ៍ Nuremberg ក៏ដោយ។

៦. តាមរយៈការស្រាវជ្រាវជាបន្តបន្ទាប់ ដែលបានធ្វើឡើងដោយមេធាវីការពារ វាហាក់ដូចជាថា សេចក្តីសម្រេចក្រោយមកនេះ គឺជាសេចក្តីសម្រេចរបស់ UNGA លេខ ៤៨៨(V) ដែលបានអនុម័តកាលពីថ្ងៃទី១២ ធ្នូ ១៩៥០[25]។ សេចក្តីសម្រេចរបស់ UNGA លេខ ៤៨៨(V) បានយោងទៅលើសេចក្តីសម្រេចលេខ ៩៥(I) របស់ UNGA ក៏ដូចជា សេចក្តីសម្រេចលេខ ១៧៧(II) របស់ UNGA ចុះថ្ងៃទី២១ វិច្ឆិកា ១៩៤៧[26] ដែលបានណែនាំឱ្យគណៈកម្មាធិការច្បាប់ អន្តរជាតិរៀបចំតាក់តែងគោលការណ៏ Nuremberg ។ យោងតាមគណៈកម្មាធិការច្បាប់អន្តរជាតិនេះ សេចក្តីសម្រេចលេខ ៤៨៨(V) ចែងថា “គណៈកម្មាធិការច្បាប់អន្តរជាតិបានតាក់តែងគោលការណ៍មួយចំនួន ដែលបានទទួលស្គាល់នៅក្នុងធម្មនុញ្ញ និងសាលក្រមរបស់សាលាជម្រះក្តី Nuremberg ហើយមានប្រតិភូជាច្រើនបានធ្វើសេចក្តីសង្កេតការណ៍នៅក្នុងសម័យប្រជុំលើកទី ៥ របស់មហាសន្និបាតអង្គការសហប្រជាជាតិស្តីពីការរៀបចំកាត់តែងគោលការណ៍នេះ”[27]។ ដូច

---

[25] សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ ៤៨៨(V), កិច្ចប្រជុំពេញអង្គលើកទី ៣២០, ថ្ងៃទី១២ ធ្នូ ១៩៥០។

[26] សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ ១៧៧(II), កិច្ចប្រជុំពេញអង្គលើកទី ១២៣, ថ្ងៃទី២១ វិច្ឆិកា ១៩៤៧។

[27] ដូចយោងខាងលើ។ គូសបញ្ជាក់បន្ថែម។

ដែលបានលើកឡើងនៅក្នុងរបាយការណ៍របស់អ្នករាយការណ៍ពិសេស J. Spiropoulos កាលពីថ្ងៃទី១២ មេសា ១៩៥០[28] ហើយដែលបានពង្រឹងបន្ថែមទៀតក្នុងរបាយការណ៍បន្ទាប់ក្រោយមកទៀតរបស់ គណៈកម្មាធិការច្បាប់អន្តរជាតិ ខែកក្កដា ១៩៥០[29] គោលការណ៍ Nurembergដែលបានតាក់តែងឡើងដោយគណៈកម្មាធិការច្បាប់អន្តរជាតិនេះ មិនបានដាក់បញ្ចូលការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះផែនការរួម សម្រាប់ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ[30]។ ថ្វីបើរបាយការណ៍ទាំងនោះពិតជារាប់បញ្ចូលនូវគោលការណ៍ទាំងឡាយដែល ក.ស.ព[31] បានលើកឡើងមែនក៏ដោយ ក៏របាយការណ៍ទាំងនេះគ្មានបានលើកឡើងអ្វីទាំងអស់ អំពីការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះផែនការរួម សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ឡើយ។

៧. សាស្ត្រាចារ្យ Scharf បានសារភាពយ៉ាងចំហរថា គាត់ (ក្នុងឋានៈគាត់ជាជំនួយការពិសេស) និងបុគ្គលិករបស់ ក.ស.ព បានដឹងច្បាស់ថា មានសេចក្ដីសម្រេចក្រោយមកមួយទៀតរបស់ UNGA ដែលហាក់ដូចជាធ្វើឱ្យអន្តរាយយ៉ាងខ្លាំងដល់ទឡ្ហីករណ៍របស់ ក.ស.ព ទាក់ទងទៅនឹងការអនុវត្តសហកម្មឧក្រិដ្ឋកម្មរួម។ នៅចុងបញ្ចប់នៃការបង្រៀនរបស់គាត់ សាស្ត្រាចារ្យ Scharf

---

28 ការតាក់តែងគោលការណ៍ Nuremberg (the Nuremberg Principles)។ របាយការណ៍របស់ J. Spiropoulos អ្នករាយការណ៍ពិសេស (Special Rapporteur) ចុះថ្ងៃទី១២ មេសា ១៩៥០ លេខ A/CN.4/22 ។

29 របាយការណ៍របស់គណៈកម្មាធិការច្បាប់អន្តរជាតិ នៅក្នុងសម័យប្រជុំលើកទី ២ របស់ខ្លួន កាលពីថ្ងៃទី ៥ មិថុនា ដល់ថ្ងៃទី ២៩ កក្កដា ១៩៥០ កំណត់ហេតុផ្លូវការរបស់មហាសន្និបាត អ.ស.ប សម័យប្រជុំលើកទី ៥ សេចក្ដីបំពេញបន្ថែមលេខ 12(A/1316)។

30 គោលការណ៍ទាំងប្រាំ ដែលបានកំណត់នៅក្នុងផ្នែកទី III នៃរបាយការណ៍របស់គណៈកម្មាធិការច្បាប់អន្តរជាតិគឺៈ (១) ជនទាំងឡាយណាដែលប្រព្រឹត្ត ឬ ជាអ្នកសមគំនិតនៅក្នុងការប្រព្រឹត្តអំពើមួយ ដែលបង្កទៅជាឧក្រិដ្ឋកម្មនៅក្រោមច្បាប់អន្តរជាតិ ត្រូវទទួលខុសត្រូវ និងទទួលរងការផ្ដន្ទាទោសចំពោះអំពើនោះ។ (២) ករណីដែលច្បាប់ជាតិមិនផ្ដន្ទាទោសចំពោះអំពើមួយដែលជាឧក្រិដ្ឋកម្មអន្តរជាតិ គឺមិនមានន័យថា ត្រូវឱ្យអ្នកប្រព្រឹត្តឧក្រិដ្ឋកម្មនោះរួចផុតពីការទទួលខុសត្រូវនៅក្រោមច្បាប់អន្តរជាតិនោះទេ។ (៣) កត្តាដែលបុគ្គលម្នាក់បានប្រព្រឹត្តឧក្រិដ្ឋកម្មអន្តរជាតិ ដោយបានប្រព្រឹត្តឡើងក្នុងឋានៈជាប្រមុខរដ្ឋ ឬ ជាមន្ត្រីសាធារណៈ គឺមិនសំដៅឱ្យជននោះរួចផុតពីការទទួលខុសត្រូវនៅក្រោមច្បាប់អន្តរជាតិ ឬ បន្ធូរបន្ថយការផ្ដន្ទាទោស នោះទេ។ (៤) បញ្ហាដែលជនម្នាក់បានប្រព្រឹត្តតាមបញ្ជារបស់រដ្ឋាភិបាលខ្លួន ឬរបស់ថ្នាក់លើ គឺមិនសំដៅថា ត្រូវឱ្យជននោះរួចផុតពីការទទួលខុសត្រូវនៅក្រោមច្បាប់អន្តរជាតិនោះទេ។ ប៉ុន្តែ វាអាចត្រូវបានពិចារណាចំពោះការបន្ធូរបន្ថយទោស ប្រសិនបើយុត្តិធម៌តម្រូវឱ្យធ្វើបែបនោះ។ (៥) ជនទាំងឡាយដែលទទួលរងការចោទប្រកាន់ពីបទឧក្រិដ្ឋនៅក្រោមច្បាប់អន្តរជាតិ ត្រូវមានសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ តាមអង្គហេតុ និងអង្គច្បាប់។

31 សេចក្ដីសង្កេតបន្ថែមរបស់ ក.ស.ព កថាខណ្ឌទី ១២ ។

ក៏បានស្នើឡើងផងដែរថា ព័ត៌មានដែលគាត់បានលាតត្រដាងនៅក្នុងការធ្វើបាឋកថានេះទាក់ទងទៅនឹងការធ្វើការងារផ្ទៃក្នុងរបស់ ក.ស.ព មិនត្រូវបានលាតត្រដាងឲ្យអ្នកណាម្នាក់ដែលមិនមានវត្តមាននៅក្នុងបន្ទប់ធ្វើបាឋកថានោះដឹងឡើយ ដែលនេះវាហាក់ដូចជាទទួលស្គាល់ថា ក.ស.ព ខកខានមិនបានបំពេញកាតព្វកិច្ចជាមូលដ្ឋានរបស់ខ្លួន ដែលមិនត្រូវលាក់លៀមចំពោះតុលាការ។ សន្មតថាការសារភាពរបស់សាស្ត្រាចារ្យ Scharf គឺជាការពិតមែននោះ នោះសាស្ត្រាចារ្យ Scharf និងបុគ្គលិករបស់ ក.ស.ព ពិតជាបានរួមគំនិតគ្នាដោយមិនពិចារណាវែងឆ្ងាយ ក្នុងចេតនាដើម្បីបំភ័ន្ត និងបញ្ឆោត ក.ស.ច.ស អោយយល់ខុស។

៨. យោងទៅតាមប្រវត្តិរូបសង្ខេបរបស់គាត់ដែលគេអាចស្វែងបានជាសាធារណៈ[32] សាស្ត្រាចារ្យ Scharf បានក្លាយជាសមាជិកនៃគណៈមេធាវីតំបន់ District of Columbia ចាប់តាំងពីឆ្នាំ ១៩៨៩ ។ ចាប់តាំងពីឆ្នាំ ១៩៨៩ សហព្រះរាជអាជ្ញាអន្តរជាតិ Robert Petit "បានបំរើការងារទាំងជារដ្ឋអាជ្ញាខេត្ត (Quebec) និងសហព័ន្ធ [កាណាដា] [33]" និងនៅមុនពេលមកធ្វើការងារនៅ អ.វ.ត.ក គាត់ធ្លាប់បានបំរើការងារជា "មេធាវីជាន់ខ្ពស់ (Senior Trial Attorney) នៅតុលាការពិសេសសម្រាប់សៀរ៉ាលេអូន" [34]។ សមាជិកដទៃទៀតរបស់ ក.ស.ព ដែលមេធាវីការពារក្តីជឿរថាបានចូលរួមក្នុងការរៀបចំតាក់តែងរបាយការណ៍សង្កេតបន្ថែមរបស់ ក.ស.ព ក៏ធ្លាប់បានបំរើការងារពីមុននៅតុលាការ ICTY ផងដែរ។ ដូចដែលមានរៀបរាប់ខាងលើ បទបញ្ញត្តិនីមួយៗនៃក្រមសីលធម៌ទាំងនេះ ដែលចងកាតព្វកិច្ចសមាជិកនានារបស់ ក.ស.ព ហាមឃាត់ការបំភ័ន្តតុលាការអោយយល់ខុសដោយដឹងជាមុន និងដោយមានចេតនា រួមមាន ក.ស.ច.ស ផងដែរ។

៩. ជាអ្នកបំរើរបស់តុលាការ វាជាកាតព្វកិច្ចជាសារវ័ន្តរបស់មេធាវីទាំងអស់ដែលប្រកបវិជ្ជាជីវៈនៅចំពោះតុលាការនានា (ជាតិ អន្តរជាតិ តុលាការបែបអន្តរជាតិ ឬតុលាការកូនកាត់) មិនបំភ័ន្តតុលាការនេះអោយយល់ច្រលំឡើយ។ បញ្ហាស្មុគស្មាញនៃបញ្ហាជុំវិញ JCE បណ្តាលអោយកិច្ចជាជំនួយការដែលមានតម្លាភាព និងបើកចំហរពីសំណាក់អយ្យការ និងមេធាវីការពារក្តី ដែលមានវត្តមានការពារក្តីក្តីនៅចំពោះ អ.វ.ត.ក មានសារៈសំខាន់ជាខ្លាំង។ នៅពេលសម្រេចទៅលើបញ្ហា

---

[32] *សូមមើល* ប្រវត្តិរូបសង្ខេបរបស់ Michael Scharf ដែលអាចរកបាននៅគេហទំព័ររបស់សាកលវិទ្យាល័យ Case Western Reserve នៅhttp://law.case.edu/faculty/cv/scharf.pdf/.

[33] *សូមមើល* ជីវប្រវត្តិរបស់ Robert Petit នៅលើគេហទំព័ររបស់ អ.វ.ត.ក http://www.eccc.gov.kh/english/prosecutors.aspx.

[34] *ដូចយោងខាងលើ*។

ស្មុគស្មាញពាក់ព័ន្ធនឹងចំណោទនៃច្បាប់អន្តរជាតិ អត្ថិភាពនៃការត្រួតពិនិត្យមូលដ្ឋានសំអាងផ្លូវច្បាប់ប្រើប្រាស់ជាឯកសារយោង គឺខុសឆ្ងាយពីភាពជាក់ស្តែងណាស់។ ជាទូទៅ វាក៏មិនអាចទៅរួចឡើយដើម្បីអោយភាគីមួយនៃកិច្ចដំណើរការនីតិវិធីអាចបង្ហាញភស្តុតាងថា ការខកខានមិនបានផ្តល់ព័ត៌មានជាក់លាក់របស់ភាគីមួយទៀត គឺជាការធ្វើដោយមានបំណងព្យាបាទ ក្រៅពីថាភាគីនោះធ្វើ គឺដោយសារការមិនបានដឹងអំពីមូលដ្ឋានសំអាងផ្លូវច្បាប់ប្រើប្រាស់ជាឯកសារយោងផ្ទុយពីនេះ។ ចំពោះករណីឥឡូវនេះ សាស្ត្រាចារ្យ Scharf បានទទួលស្គាល់ថា ក.ស.ព ដែលជាភាគីមួយនៃនីតិវិធីត្រូវបានចងភ្ជាប់ដោយការហាមឃាត់ផ្នែកក្រមសីលធម៌ និងផ្នែកវិជ្ជាជីវៈ ក.ស.ព បានដឹងពីធាតុពិតនៃមូលដ្ឋានសំអាងផ្លូវច្បាប់ប្រើប្រាស់ ដែលកំពុងប្រើជាឯកសារយោង ហើយបន្ទាប់ពីបានពិភាក្សាគ្នាយ៉ាងហ្មត់ចត់ សម្រេចជ្រើសរើសដោយខ្លួនឯងច្បាស់លាក់កំបាំងការពិត (ដោយសន្មតថា ការគាំទ្ររបស់សាស្ត្រាចារ្យ Scharf មិនមានគុណភាព)[35] ដោយមិនបានធ្វើការយោងជាសំអាងទៅលើសេចក្តីសម្រេចរបស់ UNGA ក្រោយមកទៀតនោះ។

១០. ជាការគួរឲ្យសោកស្តាយ វាដូចជារឿងក្តីបុរាណមួយស្តីពី *ក្រមសីលធម៌អនុវត្តទៅតាមស្ថានការណ៍* (situational ethics) ដែលនៅពេលនោះ *លទ្ធផលយកមកធ្វើជាយុត្តិកម្មសម្រាប់ការប្រើប្រាស់មធ្យោបាយ* (the ends justify the means) មានន័យថា ក.ស.ព ផ្តល់សារៈសំខាន់ជាខ្លាំងចំពោះ ក្នុងការអនុវត្តសហកម្មឧក្រិដ្ឋកម្មរួមនៅ អ.វ.ត.ក ជាជាងការគោរពកាតព្វកិច្ចខាងក្រមសីលធម៌របស់ខ្លួន។ សួរថា បើសិនជាមិនមែនដោយសារក្តីរំភើបទេនោះ តើហេតុអ្វីបានជាសាស្ត្រាចារ្យ Scharf មានឆន្ទៈខ្លាំងក្លាយល់ព្រមជួយជ្រោមជ្រែង ក.ស.ព ដោយស្ងាត់ៗ ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ ក.ស.ព ដើម្បីបំភាន់ ក.ស.ច.ស ទៅវិញ។ សំណួរនឹងចោទទៅលើគុណតម្លៃនៃការពឹងផ្អែកទៅលើសាស្ត្រាចារ្យ Scharf និងមនុស្សដែលមានលក្ខណៈដូចគាត់នេះ ក្នុងនាមជាអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ផ្នែកច្បាប់ (legal scholars) ជាអប្បបរិមាគឺជាមនុស្សដែលគេរំពឹងថាមានភាពស្មោះត្រង់ខាងផ្លូវបញ្ញា (intellectual intergrity)នោះ។

---

[35] ស្តែងចេញពីចំណាប់អារម្មណ៍ដែលមានចំពោះអ្នកបានចូលរួមមានវត្តមាននៅក្នុងការធ្វើបាឋកថានោះ វាទំនងជាថាសាស្ត្រាចារ្យ Scharf មានមោទនភាព និងការពេញចិត្តចំពោះការចូលរួមរបស់គាត់ជាមួយនឹងសមាជិករបស់ ក.ស.ព ក្នុងការធ្វើយុទ្ធសាស្ត្រថា តើគួរត្រូវមានភាពស្មោះត្រង់ទាំងស្រុងជាមួយ ក.ស.ច.ស ហើយប្រថុយអោយមានភាពទន់ខ្សោយក្នុងទឡ្ហីករណ៍របស់ខ្លួនដើម្បីគាំទ្រការអនុវត្តនូវ JCE ចំពោះមុខ អ.វ.ត.ក ឬ ក៏ត្រឹមតែលាក់កំបាំងនូវការពិតដើម្បីទទួលបានប្រយោជន៍នោះដែរឬទេ។

## IV. សំណូមពរ

អាស្រ័យហេតុនេះ សម្រាប់ហេតុផលដែលបានលើកឡើងនៅក្នុងសំណើនេះ មេធាវីការពារសូមស្នើដោយគោរពសុំឲ្យ ក.ស.ច.ស៖

ក. **បង្គាប់ឲ្យ** ក.ស.ព ដាក់សំណើសុំកែកំហុសមួយចំពោះសេចក្តីសង្កេតបន្ថែមរបស់ខ្លួនទាក់ទងទៅនឹងផលប៉ះពាល់ទៅលើសេចក្តីសម្រេចលេខ ៩៥ (I) របស់ មហាសន្និបាត អ.ស.ប ដោយសាររបាយការណ៍ឆ្នាំ ១៩៥០ របស់គណៈកម្មាធិការច្បាប់អន្តរជាតិ និងសេចក្តីសម្រេចលេខ ៤៨៨ (V) របស់មហាសន្និបាត អ.ស.ប និង សេចក្តីសម្រេចដទៃផ្សេងទៀតរបស់មហាសន្និបាត អ.ស.ប ដែលមានផលប៉ះពាល់មកលើឋានៈនៃគោលការណ៍ Nuremberg **និង**

ខ. **ដោះស្រាយ**បញ្ហាដោយសង្ខេបតាមវិធានផ្ទៃក្នុង ៣៥(២) ដោយដាក់ទណ្ឌកម្មសហព្រះរាជអាជ្ញាអន្តរជាតិ ឬបុគ្គលិកនានារបស់ ក.ស.ព ចំពោះការធ្វើឲ្យតុលាការយល់ច្រលំដោយមានចេតនា និងជូនដំណឹងដល់គណៈមេធាវីនីមួយៗរបស់ពួកគេអំពីការរកឃើញនេះ[36] **ឬ**

គ. **ធ្វើ**ការស៊ើបអង្កេតបន្ថែមទៅលើការរំលោភបំពានកាតព្វកិច្ចនៃក្រមសីលធម៌របស់ ក.ស.ព រួមទាំង ការស្តាប់ចម្លើយសាស្ត្រាចារ្យ Scharf និងបុគ្គលិកដទៃទៀតរបស់ ក.ស.ព ដែលទទួលខុសត្រូវចំពោះការដាក់សេចក្តីសង្កេតបន្ថែមរបស់របស់ ក.ស.ព។

សូមលោកសហចៅក្រមទទួលយកសំណើសុំនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **២៩ ខែមិថុនា ឆ្នាំ ២00៩**

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី** ។

[36] អំណាចនេះ ទំនងជាស្ថិតនៅក្នុងយុត្តាធិការពិតប្រាកដមែនរបស់ ក.ស.ច.ស ហើយដែលវាក៏ធ្លាប់ត្រូវបានប្រើប្រាស់កាលពីពេលមុននេះដែរ ។ *សូមមើល ករណី អៀង សារី* សំណុំរឿង 00២/១៩-0៩-២00៧-អវតក/កសចស ដីកាសម្រេចស្តីពីការរំលោភបំពានភាពសម្ងាត់នៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ៣ មីនា ២00៩ ទំព័រ ៧ ។